**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា**

# សេចក្តីថ្លែងការណ៍
## របស់អ្នកនាំពាក្យគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
## ស្តីពីការរៀបចំច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

***អ្នកនាំពាក្យគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា*** សូមជម្រាបជូនសាធារណជនទាំងអស់មេត្តាជ្រាបថា ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ត្រូវបានរៀបចំឡើងអនុលោមតាមស្មារតីនៃមាត្រា ២២ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលការសម្រេចដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន គឺត្រូវធ្វើឡើងនៅពេលដែលប្រទេសជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ដែលបណ្តាលមកពី ជាអាទិ៍ គ្រោះថ្នាក់ដែលបង្កឡើងដោយសង្គ្រាម ឬការឈ្លានពានពីកម្លាំងបរទេស គ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈ បណ្តាលមកពីការឆ្លងរាលដាលនៃជំងឺ ភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងគ្រោះធ្ងន់ធ្ងរ ដែលគំរាមកំហែង ឬអាចបង្កគ្រោះថ្នាក់រីករាលដាលដល់កម្រិតទូទាំងប្រទេស។

ការរៀបចំច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន មិនមានចរិតជាការរំលោភសិទ្ធិមនុស្ស ឬជាឧបករណ៍ប្រមូលអំណាច ដូចការចោទប្រកាន់បែបអគតិរបស់ក្រុមប្រឆាំងមួយក្តាប់តូចនោះទេ តែផ្ទុយទៅវិញ ច្បាប់នេះ គឺជាឧបករណ៍គតិយុត្តដ៏មានតម្លៃក្នុងការការពារសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបាននូវសន្តិភាព ស្ថិរភាពសង្គម និងការអភិវឌ្ឍ ដែលជាក្តីប្រាថ្នាចង់បានរបស់ប្រជាពលរដ្ឋទូទាំងប្រទេស និងស្របតាមគោលការណ៍នីតិរដ្ឋនៅក្នុងសង្គមប្រជាធិបតេយ្យ។ ច្បាប់នេះ ក៏នឹងផ្តល់ជាមូលដ្ឋានគតិយុត្តដល់ការអនុវត្តមាត្រា២២ថ្មី នៃរដ្ឋធម្មនុញ្ញផង និងជាមូលដ្ឋានគតិយុត្តកំណត់ពីសិទ្ធិអំណាចរបស់រាជរដ្ឋាភិបាល ក្នុងការដាក់ចេញនូវវិធានការនានា ដែលមានចរិតជាការហាមឃាត់ ឬការកម្រិតនូវសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ប៉ុន្តែវិធានការនេះ មានភាពចាំបាច់មិនអាចខ្វះបានដើម្បីឆ្លើយតបទៅនឹងស្ថានភាពរបស់ប្រទេសជាតិក្នុងគ្រាអាសន្ន សំដៅការពារសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ការពារអាយុជីវិត និងសុខភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងការពារទ្រព្យសម្បត្តិ និងបរិស្ថាន។

ការរៀបចំច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន មិនមែនជាករណីដោយឡែកសម្រាប់កម្ពុជានោះទេ ពោលគឺបណ្តាប្រទេសប្រជាធិបតេយ្យជាច្រើនផ្សេងទៀត ក៏មានច្បាប់នេះសម្រាប់គ្រប់គ្រងប្រទេសជាតិរបស់គេក្នុងស្ថានភាពគ្រាអាសន្ននេះដែរ ហើយដែលអនុញ្ញាតដោយបទដ្ឋានសិទ្ធិមនុស្សជាតិនិងអន្តរជាតិ រួមមាន រដ្ឋធម្មនុញ្ញកម្ពុជា (មាត្រា២២ថ្មី, មាត្រា៣១, មាត្រា៨៦ និងមាត្រា១០២ថ្មី) សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា២៩, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា៤, ការបកស្រាយរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ, រួមទាំងសេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិជាដើម ។ល។

បើពិនិត្យទៅលើការអនុវត្តជាអន្តរជាតិ និងបណ្តាប្រទេសប្រជាធិបតេយ្យមួយចំនួនក្នុងតំបន់ សេចក្តីព្រាងច្បាប់របស់កម្ពុជាប្រកាន់នូវបទដ្ឋាន និងស្តង់ដារកណ្តាលមួយ ពោលគឺមិនតឹងរ៉ឹងជាងគេពេក ហើយក៏មិនធូររលុងជាងគេពេកដែរ ដោយកម្ពុជាបានធ្វើការសិក្សាពីគំរូនៃការអនុវត្តរបស់បណ្តាប្រទេសប្រជាធិបតេយ្យទាំងនោះ រួមទាំងបរិបទរបស់កម្ពុជាផងដែរ។ ក្នុងការអនុវត្តជាអន្តរជាតិ ប្រទេសមួយចំនួនប្រកាន់យកបទដ្ឋានតឹងរ៉ឹងនិងធ្ងន់ធ្ងរ ដោយប្រគល់អំណាចទាំងអស់ ទៅដល់ស្ថាប័ននីតិប្រតិបត្តិក្នុងការចាត់គ្រប់វិធានការចាំបាច់គ្រប់បែបយ៉ាងទាំងអស់ ដោយគ្មានការត្រួតពិនិត្យឡើយ ចំណែកឯប្រទេសមួយចំនួនទៀត គឺអនុញ្ញាតឱ្យមានយន្តការត្រួតពិនិត្យពីសភា ឬ/និងតុលាការ ហើយក្នុងករណីគ្រោះអាសន្នធ្ងន់ធ្ងរប៉ះពាល់ដល់សន្តិសុខជាតិ គឺអនុញ្ញាតឱ្យប្រើប្រាស់នូវច្បាប់អាជ្ញាសឹកទៅទៀត។

សម្រាប់បញ្ញត្តិនៃសេចក្តីព្រាងច្បាប់របស់កម្ពុជាវិញ គឺមិនបានផ្តល់អំណាចទៅឱ្យស្ថាប័ននីតិប្រតិបត្តិក្នុងការចាត់គ្រប់វិធានការ ដោយគ្មានដែនកំណត់នោះទេ ពោលគឺត្រូវស្ថិតក្រោមយន្តការនៃការត្រួតពិនិត្យរបស់សភារហូតទៅដល់ពីរថ្នាក់គឺ រដ្ឋសភា និងព្រឹទ្ធសភា តាមរបបប្រជាធិបតេយ្យបែបសភានិយម រួមទាំងការទទួលខុសត្រូវតាមផ្លូវច្បាប់របស់សមត្ថកិច្ចផងដែរ ដែលប្រើប្រាស់សិទ្ធិអំណាចតាមទំនើងចិត្ត ដោយរំលោភបំពានខុសពីគោលបំណងនៃច្បាប់នេះ។

***អ្នកនាំពាក្យគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា*** ក៏សូមឆ្លៀតយកឱកាសនេះ ធ្វើការអំពាវនាវដល់សាធារណជនទាំងអស់ផងដែរ កុំឱ្យមានការព្រួយបារម្ភពីការរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់នេះ ពោលគឺសូមមានទំនុកចិត្ត និងការជឿជាក់លើវិធានការរបស់រាជរដ្ឋាភិបាលដឹកនាំដោយ **សម្តេចតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការគ្រប់គ្រងស្ថានការណ៍ប្រកបដោយភាពប៉ិនប្រសប់ ឈ្លាសវៃ និងការទទួលខុសត្រូវខ្ពស់ ចំពោះសុខទុក្ខរបស់ជាតិ និងប្រជាពលរដ្ឋខ្មែរ ដោយហេតុថា ការប្រកាសដាក់ប្រទេសក្នុងភាពអាសន្ន ហើយឈានទៅការអនុវត្តបញ្ញត្តិនៃច្បាប់នេះ គឺនឹងត្រូវពិចារណាក្នុងករណីដែលចាំបាច់បំផុតក្នុងគោលដៅការពារ ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ រួមទាំងអាយុជីវិត សុខភាព ផលប្រយោជន៍និងទ្រព្យសម្បត្តិរបស់ពលរដ្ឋ និងសង្គមជាតិទាំងមូល។

ថ្ងៃចន្ទ ៦រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០
**អ្នកនាំពាក្យគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា**